# ស្ថានទូតអូស្ត្រាលី ភ្នំពេញ

## សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី ៤ ខែ ធ្នូ ឆ្នាំ២០២០

## ទិវាអ្នកស្ម័គ្រចិត្តអន្តរជាតិ៖ សូមថ្លែងអំណរគុណដល់អ្នកស្ម័គ្រចិត្ត ដែលជួយគាំទ្រការអភិវឌ្ឍ នៅកម្ពុជា

ទំនាក់ទំនង និងមិត្តភាព រវាងអ្នកស្ម័គ្រចិត្តអូស្ត្រាលី និងសមភាគីកម្ពុជា នឹងត្រូវបានទទួលស្គាល់ និងអបអរ នៅថ្ងៃស្អែកនេះ ក្នុងឱកាសទិវាអ្នកស្ម័គ្រចិត្តអន្តរជាតិ (៥ធ្នូ)។ ទិវាអ្នកស្ម័គ្រចិត្តអន្តរជាតិ ត្រូវបានបង្កើតឡើង ដោយអង្គការសហប្រជាជាតិ (UN) ក្នុងឆ្នាំ១៩៨៥ ដើម្បីទទួលស្គាល់នូវការចូលរួមចំណែកដ៏មានតម្លៃ របស់អ្នកស្ម័គ្រចិត្ត ក្នុងការជួយដល់ ការអភិវឌ្ឍអន្តរជាតិ នៅជុំវិញពិភពលោក។

ឯកឧត្តម Pablo Kang អគ្គរាជទូតអូស្ត្រាលីប្រចាំកម្ពុជា បានមានប្រសាសន៍ថា ការដែលទទួលស្គាល់នូវតម្លៃរបស់អ្នកស្ម័គ្រចិត្តអន្តរជាតិ ដែលពោរពេញដោយជំនាញ នៅឆ្នាំ២០២០នេះ ពិតជាមានសារសំខាន់ជាងពេលណាៗទាំងអស់។ ឯកឧត្តម បានបញ្ជាក់ថា "ផលប៉ះពាល់នៃជម្ងឺកូវីដ-១៩ ទៅលើសហគមន៍នៅកម្ពុជា ពិតជាមានទំហំធំ ហើយទោះបីជាឆ្នាំនេះជាឆ្នាំ ដែលអ្នកស្ម័គ្រចិត្តអូស្ត្រាលី និងអង្គការដែលពួកគេជួយ បានជួបនូវការលំបាកច្រើន ប៉ុន្តែពួកគេនូវតែរកឃើញវិធីដោះស្រាយជានិច្ច។"

ចាប់តាំងពីឆ្នាំ១៩៨៤ មក អ្នកស្ម័គ្រចិត្តអន្តរជាតិ ដែលមានជំនាញ បានជួយគាំទ្រការអភិវឌ្ឍនៅកម្ពុជា ដោយចូលរួមជាមួយអង្គការក្នុងស្រុករាប់រយអង្គការ ជួយពួកគេឲ្យសម្រេចបាននូវគោលដៅអភិវឌ្ឍន៍របស់គេ តាមរយៈកម្មវិធីស្ម័គ្រចិត្តអូស្ត្រាលី ដែលគាំទ្រដោយរដ្ឋាភិបាលអូស្ត្រាលី។

អ្នកស្ម័គ្រចិត្តអូស្ត្រាលី បានវិលត្រឡប់ទៅកាន់អូស្ត្រាលីវិញ កាលពីដើមឆ្នាំ ដោយសារតែមានផលប៉ះពាល់ពីជម្ងឺកូវីដ-១៩។ ទោះយ៉ាងណាក៏ដោយ កម្មវិធីស្ម័គ្រចិត្តអូស្ត្រាលី បានបន្តគាំទ្រអង្គការដៃគូនៅកម្ពុជា រហូតពេញមួយឆ្នាំ ២០២០ នេះ។ អ្នកស្ម័គ្រចិត្ត៩នាក់ បានជួយអង្គការដៃគូរបស់ពួកគេដោយធ្វើការតាមអ៊ីនធឺណែត ពីផ្ទះរបស់ពួកគេនៅអូស្ត្រាលី តាមរយៈកម្មវិធីស្ម័គ្រចិត្តពីចម្ងាយថ្មីមួយ។

អង្គការកម្ពុជាដើម្បីកុមារនិងការអភិវឌ្ឍន៍ ដែលធ្វើការជាមួយគ្រួសារ និងសហគមន៍ ដើម្បីលើកកំពស់ជីវភាពរស់នៅរបស់កុមារ បានបន្តការគាំទ្រដោយអ្នកស្ម័គ្រចិត្តរបស់ពួកគេ ដែលធ្វើការពីចម្ងាយបន្ទាប់ពីគេបានវិលត្រឡប់ទៅកាន់អូស្ត្រាលីវិញ ដោយផ្តល់ការប្រឹក្សា និងជំនួយតាមបណ្តាញអេឡិចត្រូនិច online ជួយរៀបចំដាក់សំណើរសុំមូលនិធិ វាយតម្លៃគម្រោងដែលបង្កើតជាធនធានបង្កើតជាប្រាក់ចំណូលសម្រាប់គ្រួសារ និងផ្សព្វផ្សាយពីការអនុវត្តប្រកបដោយសុវត្ថិភាព ការពារនឹងជម្ងឺកូវីដ-១៩ ដូចជាការពាក់ម៉ាសនិងលាងដៃ។

មជ្ឈមណ្ឌលព័ត៌មានស្ត្រីកម្ពុជា ជាអង្គការដៃគូមួយទៀតរបស់យើងនៅកម្ពុជា បានទទួលការគាំទ្រមូលនិធិ ពីគម្រោងមូលនិធិប៉ះពាល់ របស់កម្មវិធីស្ម័គ្រចិត្តអូស្ត្រាលី ដើម្បីជួយពួកគេ និងសហគមន៍ឲ្យឆ្លើយតបនឹងផលប៉ះពាល់នៃជម្ងឺកូវីដ-១៩។ មូលនិធិនេះ ផ្តល់ថវិកាសម្រាប់ ការឆ្លើយតបនឹងជម្ងឺកូវីដ-១៩ និងយុទ្ធនាការព័ត៌មានកម្ពុជា របស់មជ្ឈមណ្ឌល ដែលផ្តល់ព័ត៌មានត្រឹមត្រូវអំពីជម្ងឺកូវីដ-១៩ ជួយឲ្យពួកគេចេះការពារខ្លួនគេ គ្រួសារគេ និងសហគមន៍ ពីការរាលដាលនេះ។

ឯកអគ្គរាជទូត Kang បានមានប្រសាសន៍ថា "យើងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ នូវរបៀបដែលអ្នកស្ម័គ្រចិត្តអូស្ត្រាលី និងអង្គការដៃគូដែលពួកគេធ្វើការជាមួយ បានបន្តជួយគ្នាទៅវិញទៅមក។ ថ្ងៃនេះ យើងសូមថ្លែងអំណរគុណ អ្នកស្ម័គ្រចិត្តទាំងអស់ ចំពោះការចូលរួមចំណែករបស់ពួកគេ ក្នុងការអភិវឌ្ឍនៅកម្ពុជា ព្រមទាំងទំនាក់ទំនងដ៏យូរអង្វែង ដែលពួកគេបានបង្កើតជាមួយសហគមន៍កម្ពុជា។"

**ទំនាក់ទំនងព័ត៌មានៈ** Australian.Embassy.Cambodia@dfat.gov.au